# គណៈកម្មាធិការកូដិច (Codex)ជាតិ ប្រជុំពិនិត្យសេចក្តីព្រាងអនុក្រិត
# ស្តីពីបទបញ្ញត្តិបច្ចេកទេស ម្ហូបអាហារ

នៅទីស្តីការក្រសួងពាណិជ្ជកម្ម នារសៀលថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១០ គណៈកម្មាធិការ កូដិច(Codex) ជាតិ មានរៀបចំកិច្ចប្រជុំពិនិត្យសេចក្តីព្រាងអនុក្រិត ស្តីពីបទបញ្ញត្តិបច្ចេកទេសម្ហូបអាហារ ដែលមាន ០៩ជំពូក និង១០មាត្រា ក្រោមអធិបតីភាព ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មាធិការកូដិចជាតិ ។




មានប្រសាសន៏នាឱកាសនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានបញ្ជាក់ថាៈសេចក្តីព្រាងអនុក្រិតនេះ ជាមធ្យោបាយសំខាន់ជាមូលដ្ឋាន ផ្តល់តម្លៃឱ្យទៅជាច្បាប់ដល់បណ្តាបទបញ្ញត្តិបច្ចេកទេសម្ហូបអាហារ សម្រាប់អនុវត្ត នៅព្រះរាជាណាចក្រកម្ពុជា ទាំងចំពោះផលិតផលម្ហូបអាហារ ផលិតនៅក្នុងស្រុក ទាំងផលិតផលម្ហូបអាហារនាំចូល ។ ប៉ុន្តែដើម្បីឱ្យសេចក្តីព្រាងអនុក្រិតនេះមានលក្ខណៈសុក្រិត និងមានភាពជឿនលឿនក្នុងការពិភាក្សា ឯកឧត្តមទេសរដ្ឋមន្ត្រី បានស្នើឱ្យអង្គប្រជុំយកចិត្តទុកដាក់ខ្ពស់ ចំពោះការពិនិត្យជ្រើសរើសកំណត់កំរិតស្តង់ដាជាតិ សម្រាប់ធ្វើបញ្ញត្តិបច្ចេកទេសម្ហូបអាហារនៅកម្ពុជា។ ឯកឧត្តមបានរំលឹកថាៈ គណៈកម្មាធិការអន្តរក្រសួងសម្របសម្រួលការត្រួតពិនិត្យគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវាកម្ម និងគណៈកម្មាធិការកូដិចជាតិ ត្រូវបានបង្កើតឡើង ចាប់តាំងពីឆ្នាំ២០០១ មកម្លេះ តែគណៈកម្មាធិការនេះ មិនបានជួបពិភាក្សាគ្នាញឹកញាប់ទេ ដោយមានកិច្ចការរវល់ច្រើននិងការចរចាររបស់កម្ពុជាចូលក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO)។ ឥឡូវនេះ កម្ពុជា បានក្លាយជាសមាជិកពេញសិទ្ធិ នៃអង្គការពាណិជ្ជកម្មពិភពលោក ។ ដូច្នេះ កម្ពុជាមានកតព្វកិច្ចជាច្រើន ក្នុងការបំពេញលក្ខខ័ណ្ឌតំរូវនានា នៃអង្គការ WTO ទាំងទិដ្ឋភាពច្បាប់ និងបទដ្ឋានបច្ចេកទេស ។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានបញ្ជាក់បន្ថែមថាៈ ជាបណ្តើរៗ និងយ៉ាងយូរ១០ឆ្នាំខាងមុខទៀត ការធ្វើចរាចរ ទំនិញរឺផលិតផល ពីប្រទេសមួយ ទៅប្រទេសមួយ គឺស្ថិតនៅកំរិតពន្ធ0% ដែលពេលនោះ របាំងពាណិជ្ជកម្មសំខាន់ គឺមិនមែនរបាំងពន្ធទេ តែជារបាំងផ្នែក អនាម័យ និងភូតគាមអនាម័យ (SPS) ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានបន្ថែមថាៈអង្គការ CODEX ជាអង្គការអន្តរជាតិបានធ្វើស្តង់ដាម្ហូបអាហារសម្រាប់ពិភពលោក។ ដូច្នេះកម្ពុជាយើងមិនចាំបាច់ ចំណាយពេលវេលាក្នុងការធ្វើស្តង់ដាខ្លួនឯងទេ ។ ឯកឧត្តម បានស្នើឱ្យមន្ត្រីបច្ចេកទេស ក្នុងអន្តរក្រសួង និងជាសមាជិកវិទ្យាស្ថានស្តង់ដាជាតិ ពិនិត្យមើលបញ្ជីស្តង់ដា

របស់អង្គការ CODEX ដែលបានចែកជូនរួចហើយ រួចពិនិត្យមើលថាៈតើស្តង់ដាម្ហូបអាហារមួយណា ដែលយើងយកជាស្តង់ដាជាតិ ?មួយណាជាស្តង់ដាអាចទទួលយកបាន ក្នុងលក្ខណៈស្ម័គ្រចិត្ត ? និងស្តង់ដាមួយណា? ដែលយើងត្រូវទាត់ចោល ហើយជាកិច្ចការមានលក្ខណៈប្រញ៉ាប់បំផុត ដើម្បីឱ្យកម្ពុជាមានស្តង់ដាគ្រប់វិស័យលើម្ហូបអាហារ ក្នុងន័យពង្រឹងផលិតកម្មក្នុងស្រុក និងមានឧត្តមភាពប្រកួតប្រជែងលើទីផ្សារអន្តរជាតិ ពិសេស គឺដើម្បីរួមចំណែកដល់ការថែរក្សាសុខមាលភាពមនុស្សទូទៅ ដែលប្រើប្រាស់ម្ហូបអាហារ និងផលិតផលលើទីផ្សារ ។